ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ
## ជំនាន់ទី២១ ២២ និង ២៣

នៅសាលមហោស្រពកោះពេជ្រ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៦

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី សាស្ត្រាចារ្យ និងក្មួយៗនិស្សិត ជាទីមេត្រី !

ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមពិធីប្រគល់សញ្ញាបត្រថ្នាក់ប្រកាស-នីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ជូនដល់និស្សិតជ័យលាភីជំនាន់ទី២១ ២២ និង២៣ សរុបចំនួន ៣២២ នាក់ ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីមណ្ឌលសិក្សាបច្ចេកទេសធនាគារ នាពេលនេះ ។ ខ្ញុំសូមអបអរសាទរ និងសូមកោតសរសើរយ៉ាងខ្លាំងចំពោះស្មារតីខិតខំសិក្សាបញ្ចប់មុខជំនាញធនាគារ និងហិរញ្ញវត្ថុ ក្នុងរយៈពេល ២ឆ្នាំកន្លងមក ។ ពេលនេះ ខ្ញុំសង្កេតឃើញក្មួយៗនិស្សិតជ័យលាភីទាំងអស់ មានទឹកមុខស្រស់ស្រាយ ញញឹមញញែមស្រស់ស្រាយ សប្បាយរីករាយយ៉ាងខ្លាំង ប្រកបដោយក្តីសង្ឃឹមមុតមាំ និងជឿជាក់ទៅអនាគត ។

ខ្ញុំសូមចូលរួមអបអរសាទរជាមួយ ឪពុកម្តាយ អាណាព្យាបាល សាស្ត្រាចារ្យ និងបុគ្គលិកសិក្សា របស់ក្មួយៗ ចំពោះលទ្ធផលដ៏ល្អប្រសើរ ដែលបានឆ្លុះបញ្ចាំងតាមរយៈរបាយការណ៍របស់ លោកនាយកមណ្ឌលសិក្សាបច្ចេកទេសធនាគារមុននេះ ។ ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា លទ្ធផលនេះ គឺជាមោទនភាពរួមរបស់យើងទាំងអស់គ្នា របស់ក្មួយៗផ្ទាល់ផងរបស់ឪពុកម្តាយផង របស់សាស្ត្រាចារ្យផង របស់សាលាផង និងជាមោទនភាពរបស់ប្រទេសជាតិ



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

យើងផងដែរ ដែលបានទទួលពលរដ្ឋល្អមានការអប់រំ ហើយបានក្លាយជាគ្រាប់ពូជប្រកបដោយសក្តានុពល និងសមត្ថភាពថ្មីចូលមកបម្រើការងារ ដើម្បីរួមចំណែកអភិវឌ្ឍសង្គមជាតិមាតុភូមិយើងបន្ថែមទៀត ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ ក៏ដូចជាសាស្ត្រាចារ្យ និងបុគ្គលិកសិក្សានៃមណ្ឌលសិក្សាបច្ចេកទេសធនាគារ ដែលបានជួយបណ្តុះបណ្តាល ចែករំលែកចំណេះដឹង និងបទពិសោធន៍ល្អៗជូនដល់ក្មួយៗនិស្សិត កន្លងមក ។ លទ្ធផលដែលក្មួយៗសម្រេចបាននេះ ពិតជាបានរួមចំណែកក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍធនធានមនុស្សរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងក្នុងស្រុក ក៏ដូចជានៅក្នុងតំបន់ និងពិភពលោកស្របតាម ចរន្តនៃការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងសកលភាវូបនីយកម្ម ។ ការរីកចម្រើននៃធនធានមនុស្ស ជាពិសេសលើជំនាញធនាគារ ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរក្នុងការជំរុញឱ្យវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា អភិវឌ្ឍរីកចម្រើនបានឆាប់រហ័ស និងរឹងមាំស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី សាស្ត្រាចារ្យ និងក្មួយៗនិស្សិតជាទីមេត្រី !**

ខ្ញុំសូមជម្រាបថា សសរស្តម្ភសំខាន់ទាំងបួនរបស់រាជរដ្ឋាភិបាលសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** នៅកម្ពុជា បាននិងកំពុងដើរតួជាត្រីវិស័យសំខាន់សម្រាប់គាំទ្រដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមលើគ្រប់វិស័យ ហើយមានលក្ខណៈសមាហរណកម្មជាមួយនឹងប្រទេសក្នុងតំបន់ ក្នុងនោះ កត្តាសុខសន្តិភាព ស្ថិរភាពនយោបាយសុវត្ថិភាព សណ្តាប់ធ្នាប់និងរបៀបរៀបរយសង្គម គឺជាបុរេល័ក្ខខ័ណ្ឌដ៏សំខាន់ចាំបាច់មិនអាចខ្វះបាន សម្រាប់គាំទ្រការអភិវឌ្ឍប្រទេសជាតិ ។

ឈរលើទស្សនវិស័យនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់អាទិភាពចម្បងចំនួន៤ គឺ **ផ្លូវ ទឹក ភ្លើង និង មនុស្ស** សម្រាប់ស្ថានភាពសេដ្ឋកិច្ចសង្គមនៅកម្ពុជា ។ ក្នុងយុគសម័យ សេដ្ឋកិច្ចពុទ្ធិខាងបច្ចេកវិទ្យាព័ត៌មាន ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយ អាស្រ័យជាសំខាន់លើកត្តាធនធានមនុស្សដែលមានមូលដ្ឋានចំណេះដឹងខ្ពស់ ទូលំទូលាយសម្បូរបែប មានភាពច្នៃប្រឌិតខ្ពស់ និងមានជំនាញច្បាស់លាស់ឆ្លើយតបចំពោះតម្រូវការជាក់ស្តែង ។ ប្រការនេះ តម្រូវឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍ " **មូលធនមនុស្ស** " ក្នុងបរិបទដែលកម្ពុជាកំពុងធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចក្នុងតំបន់ ទន្ទឹមនឹងការបង្កើនរបៀបវារៈអាទិភាពវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត **ផ្លូវ ទឹក និងភ្លើង** ដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ ។

អនុវត្តតាមស្មារតីនេះ កន្លងមក ធនាគារជាតិនៃកម្ពុជា បានខិតខំរួមចំណែកបណ្តុះបណ្តាលធនធានមនុស្សយ៉ាងច្រើនលើគ្រប់រូបភាពរយៈពេលខ្លី និងវែងទាំងនៅក្នុងស្រុក និងនៅបរទេស ។ នៅក្នុងស្រុក យើងបានបង្កើតមណ្ឌលសិក្សាបច្ចេកទេសធនាគារ បញ្ជូនមន្ត្រីបុគ្គលិកទៅសិក្សានៅតាមមហាវិទ្យាល័យនានា និងបង្កើតកម្មវិធីសិក្សាប្រចាំឆ្នាំនៅទីស្នាក់ការកណ្តាល ។ នៅបរទេស យើងបញ្ជូនមន្ត្រីបុគ្គលិកយើងទៅសិក្សារយៈពេលខ្លី និងវែង ថ្នាក់បរិញ្ញាបត្រ និងអនុបណ្ឌិតក្រោមកិច្ចឧបត្ថម្ភគាំទ្រពីកម្មវិធីអាហារូបករណ៍នៃបណ្តាប្រទេសជាមិត្ត និងជំនួយបច្ចេកទេសរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF, WB, ADB, JICE, JICA និង KOICA ជាដើម ។

ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងឱ្យស្របតាមការវិវត្តនៃវិស័យសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ហើយ ការពង្រឹងសមត្ថភាព និងការគ្រប់គ្រងធនធានមនុស្ស ត្រូវបានយកចិត្តទុកដាក់ជាប្រចាំ តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស និងការជ្រើសរើសមន្ត្រីចូលបម្រើការងារ ប្រកបដោយគុណវុឌ្ឍិ ។ ធនាគារជាតិនៃកម្ពុជា បានរៀបចំការបណ្តុះបណ្តាលផ្ទៃក្នុងនូវជំនាញសំខាន់ៗ ដូចជា ភាពជាអ្នកដឹកនាំ ការវិភាគហិរញ្ញវត្ថុ និងការសិក្សា

តាមប្រព័ន្ធអនឡាញក្រោមកម្មវិធី FSI Connect របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ជាពិសេសពាក់ព័ន្ធនឹងជំនាញគណនេយ្យ សញ្ញាបត្រ CPA និងជំនាញវិភាគហិរញ្ញវត្ថុ សញ្ញាបត្រ CFA ដើម្បីពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកលើការត្រួតពិនិត្យធនាគារ ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេស តាមរយៈការចាត់បញ្ជូនមន្ត្រី-បុគ្គលិកឱ្យចូលរួមវគ្គសិក្សារយៈពេលខ្លី-វែង ការប្រជុំ ទស្សនកិច្ច និងសិក្ខាសាលាជាដើម ដែលត្រូវបានធ្វើឡើងតាមការអញ្ជើញ ការឧបត្ថម្ភរបស់ស្ថាប័នអន្តរជាតិ និងធនាគារកណ្តាលនានា ។

សមិទ្ធផលដែលទទួលបានខាងលើ អាស្រ័យដោយការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញគោលនយោបាយប្រកបដោយប្រសិទ្ធភាព ធានាបាននូវសន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងធ្វើកំណែទម្រង់លើគ្រប់វិស័យ ធ្វើពិពិធកម្មលើមូលដ្ឋានសេដ្ឋកិច្ច និងអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ឆ្នាំ២០១៣-២០១៨ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាព ហើយនិងស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ។

គោលដៅរយៈពេលវែងរបស់យើង គឺបន្តបណ្តុះបណ្តាលធនធានមនុស្សលើផ្នែកជំនាញឯកទេស ។ ពេលនេះ ក្មួយៗមានសេចក្តីរីករាយខ្លាំងណាស់ជាមួយនឹងលទ្ធផលដ៏ប្រសើរនេះ ។ បន្ទាប់ពីបានបញ្ចប់ការសិក្សា និងទទួលសញ្ញាបត្រនេះទៅ ដើម្បីឱ្យក្មួយៗទទួលបានជោគជ័យបន្ថែមទៀត សូមក្មួយៗត្រូវខិតខំព្យាយាមរៀនសូត្របន្ថែមលើផ្នែកជំនាញ និងបង្កើននូវ ៖

១/- ចំណេះដឹងផ្នែកភាសាបរទេស ព្រោះភាសាបរទេស គឺជាស្ពានសម្រាប់ចម្លងចំណេះដឹង ការងារ និងការប្រាស្រ័យទាក់ទង ខណៈពេលដែលប្រទេសកម្ពុជាយើងធ្វើសមាហរណកម្មសេដ្ឋកិច្ចចូលទៅក្នុងតំបន់ និងពិភពលោក ។

២/-ចំណេះដឹងផ្នែកព័ត៌មានវិទ្យា នឹងជួយសម្រួលយ៉ាងច្រើនដល់ការប្រើប្រាស់នូវមូលធនបញ្ញាសម្រាប់ការងារប្រចាំថ្ងៃ ។ និយាយឱ្យខ្លីទៅ ដោយសារតែបច្ចេកវិទ្យាទំនើប